00626246

លេខ/No: D427/4/10

**នៅចំពោះអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ:**

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស **(អ.ប.ជ ១០៤)**

ដាក់ជូនទៅ : អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ឯកសារ : ២៤ វិច្ឆិកា ២០១០

ភាគីអ្នកដាក់ឯកសារ : មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី

ភាសាដើម : ភាសាខ្មែរ

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 11 / 2010
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ:**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **សាធារណៈ** / Public

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីអង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹង**
**បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ជំទាស់នៅនឹងដីកាដំណោះស្រាយ**

---

| | |
|---|---|
| **ដាក់ជូនដោយ:** | **ដាក់ជូនទៅ:** |
| **មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី** | **អង្គបុរេជំនុំជម្រះ** |
| លោកស្រី ជេត វណ្ណលី | ចៅក្រម ប្រាក់ គឹមសាន |
| លោកស្រី ទី ស្រ៊ីនណា | ប្រធាន ចៅក្រម Rowan DOWNING |
| លោក វ៉ែន ពៅ | ចៅក្រម ន័យ ធុល |
| **ជំនួយការ៖** | ចៅក្រម Catherine MARCHI-UHEL |
| ហេង សុនតុន | ចៅក្រម ហួត វុទ្ធី |

ហួត គង់ឃូ

ស្ដួស ស៊ីទួន

**ចំលងជូន**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

លោក យ៉េត ចរិយា

លោក William SMITH

លោក សេង ប៊ុនឃាង

**មេធាវីការពារក្ដី:**

<u>មេធាវីការពារក្ដី អៀង សារី</u>

លោក អាង ឧត្ដម

លោក Michael G.KANAVAS

<u>មេធាវីការពារក្ដី អៀង ធីរិទ្ធ</u>

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS QC

<u>មេធាវីការពារក្ដី នួន ជា</u>

លោក សុន អារុន

លោក Michiel PESTMAN

<u>មេធាវីការពារក្ដី ខៀវ សំផន</u>

លោក ស សុវាន

លោក Jacques VERGES

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ស៊ិនសុវ៉ន　យុង ផានិត

ឡៅ ជុនធី　ហុង គឹមសួន

គង់ ពិសី　ម៉ុច សុវណ្ណារី

គឹម ម៉េងឃី

Martine JACQUIN

Annie DELAHAIE　Patrick BAUDOIN

Marie GUIRAUD　Laure DESFORGES

Françoise GAUTRY　Barnabe NEKUIE

Daniel LOSQ　Isabelle DURAND

Nicole DUMAS　Julien RIVET

Pascal AUBOIN　Phillipe CANONE

Lyma Thuy NGUYEN　Mohandev MOHAN

Olivier BAHOUGNE　Silke STUDZINSKY

Emmanuel JACOMY　Emmanuel ALTIT

Christine MARTINEAU

Elizabeth Rabesandratana

Ferdinand DJAMMEN-NZEPA

Fabienne TRUSSES-NAPROUS

# I. សេចក្តីផ្តើម

១. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់សេចក្តីអង្កេតរបស់ខ្លួនទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ("ដើមបណ្តឹងឧទ្ធរណ៍")ជំទាស់ទៅនឹងដីកាដំណោះស្រាយ[1] ("បណ្តឹងឧទ្ធរណ៍") ដែលត្រូវបានដាក់ជូនដោយសហមេធាវីការពារក្តី របស់គាត់ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១០។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា បណ្តឹងឧទ្ធរណ៍ខាងលើនេះគួរត្រូវបានបដិសេធចោល ដោយសារមូលហេតុមានចំនុចកំហុសនីតិវិធី និងមិនស្របតាមកាលៈទេសៈដែលត្រូវបានអនុញ្ញាត ដោយច្បាប់ជាធរមាន។

# II. អំពីប្រវត្តិនៃនីតិវិធី

២. កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយកំណត់បទចោទទៅលើជនជាប់ចោទ ខៀវ សំផន ក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ឧក្រិដ្ឋកម្មសង្គ្រាម) និងការរំលោភបំពានទៅក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ១៩៥៦ [2]។

៣. ដើមបណ្តឹងឧទ្ធរណ៍បានដាក់លិខិតជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនកាលពីថ្ងៃទី២១ ខែកញ្ញា ២០១០[3] ហើយនៅថ្ងៃទី ១៨ ខែតុលា ២០១០ បណ្តឹងឧទ្ធរណ៍របស់គាត់ ត្រូវបានដាក់ជូនមក អង្គបុរេជំនុំជម្រះ ("អ.ប.ជ")[4]។

៤. សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍

---

[1] បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ដែលមានលេខឯកសារ D427/4/3 ។

[2] ដីកាដំណោះស្រាយ ឯកសារលេខ D427។

[3] លិខិតជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២១ កញ្ញា ២០១០ ឯកសារលេខ D427/4។

[4] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ តុលា ២០១០។

ខាងលើកាលពីថ្ងៃទី ១៥ វិច្ឆិកា ២០១០[5] ហើយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេល ៥ថ្ងៃ ក្នុងការដាក់សេចក្តីសង្កេតរបស់ខ្លួនទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ ដោយគាំទ្រចម្លើយតបរបស់សហព្រះរាជអាជ្ញា ដែលរយៈពេល ៥ ថ្ងៃនេះ រាប់ចាប់តាំងពីថ្ងៃដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅដល់ភាគី[6]។

## III. ភាពអាចទទួលយកបាននៃសេចក្តីសង្កេត

៥. ដូចដែលបានលើកឡើងនៅក្នុងកថាខ័ណ្ឌទី៤ ខាងលើ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់សេចក្តីសង្កេតរបស់ខ្លួនក្នុងរយៈពេល៥ថ្ងៃ ចាប់តាំងពីថ្ងៃដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅឱ្យភាគី ស្របទៅតាមសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៨ តុលា ២០១០[7]។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅឱ្យភាគីតាមរយៈសារអេឡិកត្រូនិចកាលពីថ្ងៃទី ១៥ វិច្ឆិកា ២០១០ ដូច្នេះ កាលបរិច្ឆេទកំណត់ចុងក្រោយនៃការដាក់សេចក្តីសង្កេតរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺចប់ថ្ងៃសៅរ៍ ទី២០ វិច្ឆិកា ២០១០ ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ថ្ងៃទី២០ វិច្ឆិកា ២០១០ គឺជាថ្ងៃឈប់សម្រាក ហើយចំពេលថ្ងៃបុណ្យជាតិ គឺថ្ងៃទី២០ ទី២១ និងទី ២២ វិច្ឆិកា ២០១០ ដែលជាថ្ងៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ ហើយថ្ងៃឈប់សម្រាក់សំរាប់ពិធីបុណ្យជាតិនេះនឹងត្រូវពន្យាតរហូតដល់ថ្ងៃទី២៣ បន្ទាប់។ ដូច្នេះ កាលបរិច្ឆេតកំណត់សម្រាប់ដាក់សេចក្តីសង្កេតនេះគឺនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលនាំឱ្យសេចក្តីសង្កេតនេះអាចទទួលយកបាន។

## IV. សេចក្តីសង្កេតទូទៅ

---

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥.១១.២០១០។ ឯកសារ D427/4/7។

[6] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី អៀង ធិរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់ ចុះថ្ងៃទី២៨.១០.២០១០។ ឯកសារ D427/1/8។

[7] ដូចជើងទំព័រទី៦ ខាងលើ។

## ក. សេចក្តីសង្ខេបនៅលើសម្អាងនានានៅក្នុងបណ្តឹងឧទ្ធរណ៍

៦. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសម្តែងការយល់ឃើញដូចគ្នាទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ជំទាស់ទៅនឹងដីកាដំណោះស្រាយ[8] ("ចម្លើយតប") ត្រង់កឋាខណ្ឌទី៣ និង កឋាខ័ណ្ឌទី៤ ទាក់ទងទៅនឹងចំនុចជាមូលដ្ឋានដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍។

៧. នៅចំនុចដំបូងនៃបណ្តឹងឧទ្ធរណ៍ ចាប់តាំងពីកឋាខ័ណ្ឌទី១៤ ដល់កឋាខ័ណ្ឌទី៤៩ ដើមបណ្តឹងឧទ្ធរណ៍បានត្រឹមតែសរសេរអំពីចំនុចទូទៅ ទាក់ទងទៅនឹងសិទ្ធិរបស់ភាគី កាតព្វកិច្ចរបស់អង្គភាពមានសមត្ថកិច្ចរបស់តុលាការ និង ចំនុចនៃនីតិវិធីដែលធានាអំពីសិទ្ធិរបស់ភាគីក្នុងកំរិតបទដ្ឋានសមស្របដោយគ្រាន់តែជាសំណេរចង្អុលបង្ហាញបញ្ញត្តិច្បាប់[9] យុត្តិសាស្ត្រនានា[10] និងស្នាដៃនិពន្ធនិងការស្រាវជ្រាវរបស់អ្នកជំនាញ[11] តែប៉ុណ្ណោះ។ បញ្ហានេះ មិនមែនជាមូលដ្ឋានគាំទ្រដ៏រឹងមាំដែលត្រូវឆ្លើយតបនោះទេ ប៉ុន្តែបញ្ហាពីរយ៉ាងសំខាន់ដែលត្រូវវិភាគនោះគឺ ទី១ កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះវាត្រឹមត្រូវតាមកាលៈទេសៈដែរឬទេ? និង ទី២ គេត្រូវជជែកពិភាក្សាលម្អិតចំពោះចំនុចដែលត្រូវបានប្តឹងឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍នេះ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការកត់សំគាល់ច្បាស់លាស់ទៅតាមចំនុចនានាដែលត្រូវបានលើកឡើងក្នុងកឋាខ័ណ្ឌខាងក្រោម។

## ខ. សំអាងផ្លូវច្បាប់ និងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

### ខ.១. ដើមបណ្តឹងឧទ្ធរណ៍ប្រើប្រាស់កម្មវត្ថុនៃបណ្តឹងសុំមោឃៈភាពដោយភាន់ច្រលំថាជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍៖

[8] ចម្លើយតបរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ វិច្ឆិកា ២០១០។ ឯកសារ D427/4/7។

[9] ជើងទំព័រ ១៦ និងជើងទំព័រ ២២ នៃបណ្តឹងឧទ្ធរណ៍។ ឯកសារ D427/4/3។

[10] ជើងទំព័រ១៣, ១៤, ១៥, ១៧, ១៨, ១៩, ២០, ២១, ២៨ និងជើងទំព័រ ២៩ នៃបណ្តឹងឧទ្ធរណ៍។ ឯកសារ D427/4/3។

[11] ជើងទំព័រ១២, ២៥ និងជើងទំព័រ ២៦ នៃបណ្តឹងឧទ្ធរណ៍។ ឯកសារ D427/4/3។

៨. ដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយដូចដែលមានចែងនៅក្នុងវិធាន ៦៧ (៥) នៃវិធានផ្ទៃក្នុង។ វិធាន ៦៧ (៥) នេះបានយោងទៅវិធាន ៧៤ ដែលចង្អុលបង្ហាញអំពីកម្មវត្ថុ និងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

៩. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើសេចក្តីបញ្ជាក់ថា បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចដូចមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង មានភាពខុសគ្នាពីបណ្តឹងសុំមោឃភាពនីតិវិធីដោយសារមិនគោរពវិធានបញ្ញត្តិទៅលើកិច្ចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) ចំណែកឯកម្មវត្ថុនៃបណ្តឹងក៏ត្រូវតែខុសគ្នាដែរ។ អ.ប.ជ ធ្លាប់បានសម្តែងអំពីភាពខុសគ្នានេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ជំទាស់ទៅនឹងដីកាសម្រេចរបស់ ស.ច.ស ទាក់ទងទៅនឹងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងទៅនឹងការបកប្រែ[12]។ ទាំងវិធានផ្ទៃក្នុង[13] របស់ អ.វ.ត.ក ទាំងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា[14] សុទ្ធតែបានកំណត់អំពីកម្មវត្ថុដែលនាំទៅដល់ការធ្វើបណ្តឹងរបស់ភាគី ដែលចង្អុលបញ្ជាក់ថា កម្មវត្ថុដែលនាំទៅដល់ការធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេច គឺខុសគ្នាទៅនឹងកម្មវត្ថុដែលនាំដល់ការធ្វើបណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ។

១០. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ដើមបណ្តឹងឧទ្ធរណ៍បានប្រើប្រាស់ចំណងជើងក្នុងបណ្តឹងរបស់ខ្លួនមានទម្រង់ជាបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចទូទៅ[15] ប៉ុន្តែគាត់យកកម្មវត្ថុនៃបណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ និងទឡ្ហីករណ៍របស់បណ្តឹងនេះមកប្រើដោយភាន់ច្រឡំ។ យើងសូមសិក្សាលម្អិតអំពីបញ្ហានេះតាមលំដាប់លំដោយខាងក្រោម។

---

[12] សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន ជំទាស់ទៅនឹដីកាសម្រេចរបស់ ស.ច.ស អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងទៅនឹងការបកប្រែ ចុះថ្ងៃទី២០ កុម្ភៈ ២០០៩។ ឯកសារលេខ A190/I/20 កថាខ័ណ្ឌ ៣៣។

[13] វិធាន ៦៧ (៥) និងវិធាន៧៤ ស្តីពីការធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេច និងវិធាន ៤៨ និងវិធាន ៧៦ (២) ស្តីពីបណ្តឹងសុំមោឃៈភាពដោយមិនគោរពវិធានបញ្ញត្តិ។

[14] មាត្រា ២៦៧ ស្តីពីបណ្តឹងឧទ្ធរណ៍ចំពោះដីការបស់សហចៅក្រមស៊ើបសួរដោយជនត្រូវចោទ និងមាត្រា ២៥២ ស្តីពីបណ្តឹងសុំមោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិ។

[15] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ។

១១. នៅក្នុងបណ្តឹងឧទ្ធរណ៍[16]របស់ខ្លួន ដើមបណ្តឹងឧទ្ធរណ៍ហាក់បីដូចជាមានចេតនាបង្ហាញដល់ អ.ប.ជ នូវចំនុចជាមូលដ្ឋានចំនួន ២ គឺទី១ អំពីវិធានបញ្ញត្តិនានាដែលគាត់យល់ថា ក្នុងឋានៈគាត់ជាភាគី ឬជនជាប់ចោទ/ជនត្រូវចោទ គាត់ត្រូវបានធានា និងការពារសិទ្ធិ និងផលប្រយោជន៍ដោយវិធានបញ្ញត្តិទាំងអស់នោះ ហើយ ស.ច.ស ត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យបានសមស្រប[17] និងទី២ គឺគាត់បានលើកឡើងអំពីចំនុចមួយចំនួនដែលជាចំណាត់ការរបស់ ស.ច.ស ដែលស្ទើតែទាំងអស់វាគឺជាកិច្ចនៃនីតិវិធី[18] ដោយបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តតាមវិធានបញ្ញត្តិឱ្យបានសមស្រប ដោយរំលងការអនុវត្តនីតិវិធីមួយចំនួន និងបានអនុវត្តវិធាននីតិវិធីដោយមានកំហុស ឬមានការខ្វះខាត។ បន្ទាប់មក គាត់បានសម្តែងបុរេវិនិច្ឆ័យជាជម្រើសថា អ.ប.ជ អាចក្លាយជាអ្នកសមគំនិតរបស់ ស.ច.ស បើសិនជា អ.ប.ជ មិនបានដោះស្រាយតាមការទាមទាររបស់គាត់[19]។

១២. ជាសរុបមក តាមរយៈការវាយតម្លៃរបស់ខ្លួន ដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញទស្សនៈថា សិទ្ធិ និងផលប្រយោជន៍របស់គាត់ត្រូវបានរំលោភបំពានដោយសារតែកិច្ចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត រហូតដល់ការចេញដីកាដំណោះស្រាយ។ មកដល់ចំនុចនេះ វាទំនងដែលថា ដើមបណ្តឹងឧទ្ធរណ៍គិតថា ការបំពេញកិច្ចនេះគឺរំលោភទៅដល់វិធានបញ្ញត្តិ ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍រកឃើញនូវចំណាត់ការទាំងឡាយដែលបំពានដល់វិធានបញ្ញត្តិ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍គាត់នេះ គាត់មិនគួរលើកជាបណ្តឹងធម្មតានោះទេ ព្រោះវាគឺជាកម្មវត្ថុនៃបណ្តឹងសុំមោឃៈភាព ក្នុងករណីដែលគាត់រកឃើញថាកិច្ចរបស់ ស.ច.ស ពិតជាមានកំហុសមែននោះ។ ម្យ៉ាងវិញទៀត នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដើមបណ្តឹងឧទ្ធរណ៍បានយោងដល់មាត្រា២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[20] ដែលមាត្រានេះបានលើកឡើងអំពីការ

---

[16] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ តុលា ២០១០។ ឯកសារលេខ D427/4/3។

[17] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ១៤ ដល់កថាខ័ណ្ឌ៥៩។

[18] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៦១ ដល់កថាខ័ណ្ឌ១១៣។

[19] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ១១៦ ។

[20] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៥៧ និងជើងទំព័រទី៣៨ ។

សម្រេចសេចក្តីរបស់សភាស៊ើបសួរនៅក្នុងករណីបណ្តឹងសុំមោឃៈ ដោយសារមិនគោរពវិធានបញ្ញត្តិដែលស្មើដោយភាគីតែប៉ុណ្ណោះ។

១៣. ដូច្នេះ ការដាក់បណ្តឹងឧទ្ធរណ៍ដោយប្រើប្រាស់នូវកម្មវត្ថុនៃបណ្តឹងមោឃៈភាព និងការប្រើប្រាស់ទឡ្ហីករណ៍បែបនេះគឺវាមិនត្រឹមត្រូវតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានោះទេ ហើយបណ្តឹងឧទ្ធរណ៍នេះគួរត្រូវបានបដិសេធចោលដោយ អ.ប.ជ។

### ខ.២. ទឡ្ហីករណ៍ក្នុងបណ្តឹងឧទ្ធរណ៍ត្រូវបានលើកឡើងដោយមិនត្រឹមត្រូវ

១៤. ករណីភាគច្រើននៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលដើមបណ្តឹងឧទ្ធរណ៍ប្តឹងជំទាស់នោះ គឺជាករណីដែលត្រូវបានកើតឡើងតាំងពីមុនពេលចេញដីកាដំណោះស្រាយមកម្លេះ ហើយស្ទើរគ្រប់ករណីទាំងអស់ត្រូវបានប្តឹង និងដោះស្រាយរួចរាល់ហើយដោយអង្គបុរេជំនុំជម្រះ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមលើកជាឧទាហរណ៍ចំនួន ៣ ដែលរួមមានដូចខាងក្រោម៖

១. បញ្ហាបកប្រែភាសាចំពោះឯកសារ[21]៖ ដើមបណ្តឹងឧទ្ធរណ៍បានបានសម្តែងនូវការជំទាស់ជាច្រើនលើកនៅក្នុងបណ្តឹងឧទ្ធរណ៍[22] ហើយយកទឡ្ហីករណ៍នេះមកធ្វើជាសំអាងគាំទ្រដល់ការជំទាស់របស់ខ្លួនទៅនឹងដីកាដំណោះស្រាយ។ សហមេធាវីដើមបណ្តឹងសូមលើកឡើងថា បញ្ហាបកប្រែភាសានៅលើឯកសារនេះត្រូវបានដោះស្រាយរួចរាល់អស់ហើយដោយ អ.ប.ជ តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ២០ កុម្ភៈ ២00៩ ដែលដើមបណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងមកអង្គបុរេជំនុំជម្រះជំទាស់ទៅនឹងដីកាសម្រេចរបស់ ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចក្នុងការបកប្រែភាសារបស់ភាគី ហើយជាទីបំផុត អ.ប.ជ បានសម្រេចថាបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន[23] រួចហើយដែរ។

---

[21] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៦៩ ដល់កថាខ័ណ្ឌ៧៣ ។

[22] ដូចខាងលើ។

[23] ឯកសារ D190/I/20។

២. បញ្ហាការស៊ើបអង្កេតដាក់បន្ទុកជាក់ស្តែង៖ ដើមបណ្តឹងឧទ្ធរណ៍លើកឡើងអំពីភាពលំអៀងនៃការស៊ើបសួររបស់ ស.ច.ស ដោយបានចោទថា ក្នុងកិច្ចស៊ើបសួរ ស.ច.ស ផ្តោតទៅលើតែភស្តុតាងដាក់បន្ទុកច្រើនជាងភស្តុតាងដោះបន្ទុក ព្រមទាំងការប្រព្រឹត្តមកលើភាគីត្រង់ចំនុចនេះថាមិនដូចគ្នា[24]។ ដើមបណ្តឹងឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានដោយភាពមិនប្រាកដប្រជាអំពីជំហររបស់លោកចៅក្រម **Marcel LEMONDE** ដែលបានផ្សាយតាមរយៈសារពត៌មានអំពីការសម្តែងមតិរបស់គាត់នៅពេលធ្វើសន្និសីទសារពត៌មានមួយនៅថ្ងៃបន្ទាប់ពីចេញដីកាដំណោះស្រាយ ថាមតិយោបល់នេះបានសម្តែងនូវភាពលំអៀង និងមានចេតនាចង់តែរកភស្តុតាងដាក់បន្ទុក[25] ក្នុងពេលខ្លួនកំពុងមានអំណាចអនុវត្តកិច្ចស៊ើបសួរ។ នៅក្នុងនោះដែរ ដើមបណ្តឹងឧទ្ធរណ៍ទំនងជាចង់សំដៅផងដែរទៅរកទង្វើរបស់លោកចៅក្រម **Marcel LEMONDE** ក្នុងពេលដំណើរការស៊ើបសួរដែលថាមានភាពលំអៀង រហូតទៅដល់ក្រុមមេធាវីការពារក្តីបានដាក់បណ្តឹងជំទាស់ទៅ អ.ប.ជ[26] ។ ទោះបីយ៉ាងណាក៏ដោយ ករណីនេះត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយដោយ អ.ប.ជ ហើយបណ្តឹងជំទាស់ក៏ត្រូវបានបដិសេធហើយដែរ ដូច្នេះ វាមិនអាចត្រូវបានលើកឡើងជាថ្មីទៀតបានទេ ជាពិសេសនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយនេះ។

៣. ការបដិសេធសិទ្ធិក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ៖ ដើមបណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងផងដែរនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយនេះ អំពីសិទ្ធិក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[27]។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមើលឃើញថា បញ្ហានេះត្រូវបានដោះស្រាយចប់សព្វគ្រប់អស់ហើយដោយ អ.ប.ជ[28] ដូចគ្នាទៅនឹងករណីទាំងពីរខាងលើដែរ។

---

[24] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៩៥ដល់កថាខ័ណ្ឌ១០៩ ។

[25] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៩៥ ដល់កថាខ័ណ្ឌ៩៧ ។

[26] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៩៨។

[27] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៦៣ ដល់កថាខ័ណ្ឌ៦៨ ។

[28] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់ អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ឯកសារ D390/1/2/4។

១៥. ករណីទាំង៣ ខាងលើនេះ សុទ្ធតែត្រូវបានដោះស្រាយរួចរាល់អស់ ដោយបិទផ្លូវតវ៉ាផងដែរ ពោលគឺភាគីមិនអាចលើកយកមកធ្វើជាមូលដ្ឋានប្តឹងតវ៉ាទៀតបានទេ ព្រោះវាជាការខ្ជះខ្ជាយពេលវេលា និងធនធានតុលាការនៅពេលដែលទាំងអស់គ្នាបានដឹងថា វាមិនអាចទៅរួចដោយមូលហេតុភាពច្បាស់លាស់តាមបញ្ញត្តិច្បាប់ហើយនោះ។

១៦. មានករណីមួយចំនួនទៀតដែលត្រូវបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ហើយដែលវាពាក់ព័ន្ធទៅនឹងកិច្ចរបស់ ស.ច.ស មុនពេលការចេញដីកាដំណោះស្រាយ ដែលរួមមានដូចជា ភាពមិនច្បាស់លាស់នៃកិច្ចដំណើរការនីតិវិធី[29] និងកិច្ចស៊ើបសួរមិនពេញលេញ[30] ជាដើម។ ទោះបីយ៉ាងណាក៏ដោយ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ស.ច.ស បានអនុវត្តតួនាទីរបស់គាត់យ៉ាងសមស្រប អនុឡោមទៅតាមវិធាននិតិវិធីជាធរមាន ហើយដើមបណ្តឹងឧទ្ធរណ៍ខ្លួនឯងក៏បានចូលរួមចំណែកនៅក្នុងដំណើរការនៃកិច្ចទាំងនេះដែរ ដោយបានប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរផ្សេងៗជាច្រើនលើក ទាក់ទងទៅនឹងបញ្ហាទាំងពីរខាងលើនេះ[31]។

១៧. ជារួមមក បើទោះបីជាស្ថិតនៅក្នុងលក្ខខណ្ឌណាក៏ដោយ ចំនុចដែលត្រូវបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួននោះ មិនអាចជាសំអាងក្នុងការដាក់បណ្តឹងឧទ្ធរណ៍ក្រោយការចេញដីកាដំណោះស្រាយឡើយ។ វាអាចជាមូលហេតុនៃការដាក់បណ្តឹងសុំមោឃៈភាពដោយការមិនគោរពវិធានបញ្ញត្តិ ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍រកឃើញថាមានកំហុសមែននោះ និងប្រសិនបើមានយន្តការតាមផ្លូវច្បាប់ក្នុងការដាក់បណ្តឹងសុំមោឃៈភាព។

### ខ.៣. ការសំអាងទៅលើមូលដ្ឋានក្នុងការធ្វើបណ្តឹងឧទ្ធរណ៍មានការភាន់ច្រឡំ

---

[29] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៧៤ ដល់កថាខ័ណ្ឌ៨៥ ។

[30] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៨៦ ដល់កថាខ័ណ្ឌ៩៥ ។

[31] សំណើសុំបំពេញកិច្ចស៊ើបសួរជាច្រើនត្រូវបានស្នើឡើងដោយសហមេធាវីការពារក្តី ដោយរួមមានទាំងសំណើសុំទាក់ទងទៅនឹងអ្នកជំនាញផង ហើយនៅក្នុងកថាខណ្ឌ៨៩ និងកថាខណ្ឌ៩០ នៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ក៏ត្រូវបានលើកឡើងខ្លះ ផងដែរអំពីចំនុចនេះ។

១៨. ដើមបណ្ដឹងឧទ្ធរណ៍បានដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាដំណោះស្រាយ ដោយខ្លួនបានបញ្ជាក់ថា បណ្ដឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានដូចមានចែងនៅក្នុងវិធាន ៧៤ (៣)(ក) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[32]។ គាត់បានលើកឡើងថា *"បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបានយោងតាមវិធាន ៧៤ (៣)(ក) ពីព្រោះដីកាដំណោះស្រាយបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក និងយោងតាមវិធាន ២១ (១) ព្រោះដីកានេះរំលោភលើវិធានស៊ើបសួរដែលធានានូវសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្ដីដោយយុត្តិធម៌។"*

១៩. វិធាន ៧៤ (៣)(ក) បានចែងថា៖

*" ១..................................................................................................*

*២..................................................................................................*

*៣. ជនត្រូវចោទ ឬជនជាប់ចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖*

*ក. ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ "*

២០. ដើមបណ្ដឹងឧទ្ធរណ៍ហាក់បីដូចជាចង់ធ្វើការបកស្រាយវិធាន៧៤(៣)(ក) ខាងលើ ឲ្យមានន័យទូលំទូលាយហួសពីការពិត ដោយគាត់បានយោងទៅដល់វិធាន ២១ (១) ពាក់ព័ន្ធទៅនឹងការបកស្រាយវិធានផ្ទៃក្នុងដោយផ្អែកលើផលប្រយោជន៍របស់ភាគី និងបានលើកឡើងអំពីយុត្តិសាស្ត្រនៃសេចក្ដីសម្រេចនានារបស់អង្គបុរេជំនុំជម្រះ[33] ដែលតាមពិតទៅ ក្នុងចំណោមសេចក្ដីសម្រេចនោះ មានសេចក្ដីសម្រេចមួយដែលបានបដិសេធទៅនឹងការលើកឡើងរបស់ដើមបណ្ដឹងឧទ្ធរណ៍ខ្លួនឯង[34]។

២១. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងធ្វើការវិភាគ ថាតើកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ខាងលើនេះ គឺជាបណ្ដឹងឧទ្ធរណ៍ដែលបញ្ជាក់អំពីយុត្តាធិការមែនឬយ៉ាងណា? ហើយថា តើបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅ

---

[32] បណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៥០ ដល់កថាខ័ណ្ឌ៥២ ។

[33] បណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៥៣។

[34] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផន ជំទាស់ទៅនឹងដីកាសម្រេចរបស់ ស.ច.ស អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងទៅនឹងការបកប្រែ ចុះថ្ងៃទី២០ កុម្ភៈ ២០០៩។ ឯកសារលេខ A190/I/20។

នឹងដីកាដំណោះស្រាយរបស់ដើមបណ្តឹងឧទ្ធរណ៍នេះ បានចោទប្រកាន់ចំចំនុចនៃសេចក្តីបញ្ជាក់អំពីយុត្តាធិការរបស់ ស.ច.ស ក្នុងដីកាដំណោះស្រាយដែរឬទេ? ហើយពាក្យថាយុត្តាធិការនេះផ្តោតទៅលើបញ្ហាអ្វីជាមូលដ្ឋាន?

២២. កម្មវត្ថុជាក់ស្តែងដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍គឺការសម្តែងសេចក្តីមិនពេញចិត្តចំពោះលទ្ធផលនៃការស៊ើបអង្កេត ទង្វើនៃការស៊ើបអង្កេតរបស់ ស.ច.ស និងរូបភាពនៃដីកាដំណោះស្រាយទាក់ទងទៅនឹងកិច្ចដែលត្រូវបានធ្វើកន្លងមក ដែលដើមបណ្តឹងឧទ្ធរណ៍យល់ឃើញថា វាបានប៉ះពាល់ដល់សិទ្ធិរបស់គាត់។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ការលើកឡើងនេះគឺមានភាពទូទៅ ដោយមិនបានលើកជំទាស់អំពីបញ្ហាយុត្តាធិការនៃចំនុចណាមួយបន្តិចសោះ។

២៣. ពាក្យយុត្តាធិការ គឺមានន័យច្បាស់លាស់ ហើយខ្លឹមសាររបស់វាមិនជាប់ពាក់ព័ន្ធទៅនឹងនីតិវិធីជាក់ស្តែងនៅក្នុងកិច្ចស៊ើបសួរនោះទេ ប៉ុន្តែវាជាប់ទាក់ទងទៅនឹងអំណាចក្នុងការកាត់ទោសរបស់តុលាការចំពោះអត្ថិភាពនៃបទល្មើសដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ ដែលត្រូវបានចាត់ទុកថា ជាយុត្តាធិការនៃបទល្មើស[35] និងបុគ្គលដែលត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវ ឬយុត្តាធិការលើបុគ្គល[36]។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("កិច្ចព្រមព្រៀង") ត្រង់មាត្រា២ បានលើកឡើងអំពីបញ្ហាយុត្តាធិការនេះ ដែលថា អ.វ.ត.ក ត្រូវបានផ្តល់នូវយុត្តាធិការតាមអំណាចច្បាប់ ក្នុងការនាំយកឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលដែលជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោស[37]។ ចំណែកឯវិធាន ២៣ (១)(ក)[38] នៃវិធានផ្ទៃក្នុងក៏មានខ្លឹមសារប្រហាក់ប្រហែលគ្នានេះដែរ។

---

[35] ដីកាដំណោះស្រាយ កថាខ័ណ្ឌ ១២៩៩ ដល់កថាខ័ណ្ឌ១៣០៩។ ឯកសារលេខ D427។

[36] ដីកាដំណោះស្រាយ កថាខ័ណ្ឌ ១៣២៧ ដល់កថាខ័ណ្ឌ១៣២៨។ ឯកសារលេខ D427។

[37] មាត្រា ២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹតទៅនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ មិថុនា ២០០៣។ អាចរកបាននៅគេហទំព័រ https//www.eccc.gov.kh

[38] វិធាន២៣ (១)(ក) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចុះថ្ងៃទី១៩ មិថុនា ២០០៧។ អាចរកបាននៅគេហទំព័រ https//www.eccc.gov.kh

២៤. លើសពីនេះទៅទៀត ដើមបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងឲ្យចំចំនុច ជំទាស់ទៅនឹងបញ្ហាយុត្តាធិការ ដែលបានចែងនៅក្នុងដីកាដំណោះស្រាយបន្តិចសោះឡើយ។ ដីកាដំណោះស្រាយបានបញ្ជាក់អំពីបញ្ហា យុត្តាធិការ ទាំងយុត្តាធិការលើបទល្មើស ចាប់ពីកថាខ័ណ្ឌ១២៩៩ ដល់កថាខ័ណ្ឌ ១៣០៩ និងទាំង យុត្តាធិការលើបុគ្គល ចាប់ពីកថាខ័ណ្ឌ១៣២៧ ដល់ កថាខ័ណ្ឌ១៣២៨។

២៥. ការមិនបានប្តឹងជំទាស់ទៅនឹងចំនុចនៃយុត្តាធិការ និងការមិនបានលើកឡើងបន្តិចសោះអំពីបញ្ហាយុត្តាធិ ការនេះ គឺមានន័យថា ដើមបណ្តឹងឧទ្ធរណ៍មិនបានដាក់បណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃវិធាន ៧៤ (៣)(ក)នោះទេ ឬបណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវទៅតាមការអនុញ្ញាត របស់ច្បាប់។ ដូច្នេះ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ។

## V. សវនាការផ្ទាល់មាត់មិនមានភាពចាំបាច់នោះទេ

២៦. ដើមបណ្តឹងឧទ្ធរណ៍បានស្នើសុំ អ.ប.ជ ឲ្យរៀបចំសវនាការដេញដោលជាសាធារណៈក្នុងការសម្រេច សេចក្តីទៅលើបណ្តឹងឧទ្ធរណ៍នេះ[39]។ ដើមបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងអំពីមូលហេតុដែលថា សវនាការជាសាធារណៈពិតជាមានភាពចាំបាច់នោះទេ។ វិធាន ៧៧ (៣)(ខ) ចែងថា បន្ទាប់ពីបាន ពិចារណាលើការយល់ឃើញរបស់ភាគី អ.ប.ជ អាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយ ផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

២៧. សវនាការជាសាធារណៈមិនមែនជាលក្ខខណ្ឌចាំបាច់នោះឡើយ ហើយដើមបណ្តឹងឧទ្ធរណ៍ក៏មិនបាន បង្ហាញហេតុផលពីសារៈសំខាន់នៃសវនាការសាធារណៈដែរ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា ដើម្បីជាផលប្រយោជន៍នីតិវិធី និងធនធានរបស់ អ.វ.ត.ក យើងខ្ញុំសូមស្នើថា ការ សម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍នេះ គឺត្រូវធ្វើឡើងដោយផ្អែកត្រឹមតែមូលដ្ឋាននៃសេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

---

[39] បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹដីកាដំណោះស្រាយ ឯកសារលេខ D427/4/3 កថាខ័ណ្ឌ៦១។

## VI. សេចក្តីសន្និដ្ឋាន និង សំណូមពរ

២៨. ជារួមមក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សំគាល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍គឺពាក់ព័ន្ធតែចំនុចនៃកិច្ចស៊ើបអង្កេត និងចំណាត់ការរបស់ ស.ច.ស តែប៉ុណ្ណោះ ពោលគឺមិនជាប់ទាក់ទងនឹងបញ្ហាយុត្តាធិការដែលមាននិយាយនៅក្នុងដីកាដំណោះស្រាយឡើយ ហើយវិធាន ៧៤ (៣)(ក) ដែលខ្លួនយកជាមូលដ្ឋានសំអាងក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ក៏មិនត្រឹមត្រូវដែរ ពីព្រោះកម្មវត្ថុជាក់ស្តែងទាំងអស់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺជាបញ្ហានីតិវិធី មិនមែនជាបញ្ហាយុត្តាធិការឡើយ។

២៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា បណ្តឹងឧទ្ធរណ៍ដែលមិនត្រឹមត្រូវដូច្នេះ ត្រូវតែត្រូវបានសម្រេចបដិសេធចោលដោយ អ.ប.ជ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម អ.ប.ជ មេត្តាសម្រេច៖

១. ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

២. បញ្ជូនដីកាដំណោះស្រាយទៅអង្គជំនុំជម្រះសាលាដំបូងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

សូមអង្គបុរេជំនុំជម្រះ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

| ជេត វណ្ណលី | ទី ស្រ៊ុនណា | ហ៊ែន ពៅ |
|---|---|---|